01476195

**Declassified to Public**
**08 April 2021**

D234/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**លេខសំណុំរឿង: ០០៣/០៧-០៩-០៩/អ.វ.ត.ក.--ក.ស.ច.ស.**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៧**

ភាសា ៖ **អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-May-2017, 12:49
CMS/CFO: Ly Bunloung

# សេចក្តីសម្រេចលើសំណើ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់សម្ភារៈនៅក្នុងសំណុំរឿង ០០៣

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

លោក អាង ឧត្តម
លោក Michael G. KARNAVAS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ាន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

I. **ប្រវត្តិនីតិវិធី**

1. ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងនេះត្រូវបានប្រកាស កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៤ និងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

2. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ បើកកិច្ចស៊ើបអង្កេតប្រឆាំង មាស មុត និងបានស្នើឡើងនូវបទចោទជាច្រើនប្រឆាំង មាស មុត[1]។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចោទប្រកាន់ មាស មុត ពីការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មបន្ថែមផ្សេងទៀត[2]។

3. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតមុន បានចោទប្រកាន់ មាស មុត ពីបទរំលោភបំពានទៅលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (អំពើមនុស្សឃាត) ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើ អនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់ ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត[3]។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ខ្ញុំបានទុកជាមោឃៈនូវបទចោទមួយចំនួនប្រឆាំង មាស មុត ដែលសហចៅក្រមស៊ើបអង្កេតមុន បានចោទប្រកាន់ ហើយខ្ញុំបានចោទប្រកាន់គាត់ពីបទ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទចោទបន្ថែមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានទៅលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (អំពើមនុស្សឃាត)[4]។ មាស មុត ត្រូវបានចោទប្រកាន់ពី ការ

---

[1] សំណុំរឿង ០០៣ ឯកសារ D1, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, កថាខណ្ឌ ៩៩។

[2] សំណុំរឿង ០០៣ ឯកសារ D120, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានា ទាក់ទងនឹងសំណុំរឿង ០០៣, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤, កថាខណ្ឌ ២៥ ដល់២៧។

[3] សំណុំរឿង ០០៣ ឯកសារ D128, ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយកំបាំងមុខ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥។ សំណុំរឿង ០០៣ ឯកសារ D128.1, ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥។

[4] សំណុំរឿង ០០៣ ឯកសារ D174, កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

ប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នា ដូចជាការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម[5]។

4. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានជូនដំណឹងដល់ភាគីនានា អំពីការបញ្ចប់ការស៊ើបអង្កេតប្រឆាំង មាស មុត ដោយផ្តល់ដល់ភាគីនូវពេលវេលាចំនួន៣០ថ្ងៃ ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបអង្កេតបន្ថែម ("ការជូនដំណឹង") ហើយបានកាត់បន្ថយវិសាលភាព នៃកិច្ចស៊ើបអង្កេតអនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង[6]។

5. នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់សម្ភារៈទៅក្នុងសំណុំរឿង ០០៣ (“សំណើ”)[7]។ យោងតាមការណែនាំរបស់ខ្ញុំ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦[8] សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់ដល់ មេធាវីការពារក្តី មាស មុត ("មេធាវីការពារក្តី") នូវឯកសារសម្ងាត់ ជាឯកសារអេឡិចត្រូនិក ដែលជាកម្មវត្ថុនៃសំណើ បន្ទាប់ពីបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង[9]។

6. នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់ ចម្លើយតបចំពោះសំណើ (“ចម្លើយតប")[10]។

## II. **សារធាតុ**

### **ក. សំណើ**

---

[5] *ដូចដើងទំព័រខាងលើ*។

[6] សំណុំរឿង ០០៣ ឯកសារ D225, សេចក្តីជូនដំណឹងអំពីការបិទ ការស៊ើបសួរប្រឆាំង មាស មុត, ថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៧។ សំណុំរឿង ០០៣ ឯកសារ D226, ដីកាសម្រេចលើការបន្ថយវិសាលភាព នៃកិច្ចស៊ើបអង្កេត អនុលោមតាម វិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

[7] សំណុំរឿង ០០៣ ឯកសារ D234, *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់សម្ភារៈទៅក្នុងសំណុំរឿង ០០៣*, ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៧។

[8] សំណុំរឿង ០០៣ ឯកសារ D209, [កោសលប់] ដីកាសម្រេចលើសំណើរបស់ យឹម ទិត្យ សុំព័ត៌មានបន្ថែម និងឯកសារទាក់ទងនឹងសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់សម្ភារៈស្តីពីគោលនយោបាយ ប.ក.ក ទៅក្នុងសំណុំរឿង ០០៤, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦, កថាខណ្ឌ ១៣ ដល់១៤។

[9] សំណើ, កថាខណ្ឌ ៦, ៣១។

[10] សំណុំរឿង ០០៣ ឯកសារ D234/1, ចម្លើយរបស់ មាស មុត តបនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សម្ភារៈឯកសារទៅក្នុងសំណុំរឿង ០០៣, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧។

7. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំដល់ សហចៅក្រមស៊ើបអង្កេត សុំដាក់ឯកសារចំនួន ៨៦៥ឯកសារ ទៅក្នុងសំណុំរឿង ០០៣ ដែលក្នុងនោះរួមមាន៖

ក. ឯកសារសំណុំរឿង ០០២ ផែនទី និង វីដេអូ និង

ខ. ឯកសារសហកាល សម្រាប់បញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស ("បញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស") ដែលឯកសារមួយចំនួន មាននៅក្នុងសំណុំរឿង ០០២[11]។

8. ឯកសារត្រូវបានកំណត់ជាក្រុម នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយសំណើ ("ឧបសម្ព័ន្ធរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ") រួមជាមួយការពណ៌នា និងការអះអាងពីភាពពាក់ព័ន្ធរបស់ឯកសារនីមួយៗ[12]។ នៅក្នុងសេចក្តីសម្រេចនេះ ខ្ញុំយោងទៅរកឯកសារទាំងនោះ ទៅតាមលេខដែលផ្តល់ឲ្យឯកសារ នៅក្នុងឧបសម្ព័ន្ធរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ។

9. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សកម្មភាពដែលបានស្នើសុំ ដូចបានសង្ខេបខាងក្រោម គឺមានភាពជាក់លាក់គ្រប់គ្រាន់ ហើយអាចនាំទៅដល់ការស្វែងរកការពិត ទាក់ទងឧក្រិដ្ឋកម្មដែលបានលើកឡើង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលចាំបាច់សម្រាប់កិច្ចស៊ើបអង្កេត និងគោរពទៅដល់សិទ្ធិទទួលបាន ការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ មាស មុត[13]។

១. <u>ជម្លោះប្រដាប់អាវុធអន្តរជាតិ (ឯកសារ១ ដល់១៦)</u>

10. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេត ដាក់ឯកសារចំនួន១៦ ទៅក្នុងសំណុំរឿង ០០៣ ដែលពាក់ព័ន្ធនឹងការកំណត់ ពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលផ្តល់នូវសុចនាការភូមិសាស្ត្រ និងពេលវេលា នៃការឈ្លានពាននៅតាមព្រំដែន កម្ពុជាប្រជាធិបតេយ្យ វៀតណាម និងការរំលោភទៅលើបណ្តាកោះឯនាយសមុទ្រ។ ឯកសារទាំងនោះរួមមាន៖ (១) សេចក្តីរាយការណ៍ សេចក្តីថ្លែងការណ៍ជាសាធារណៈ និងឯកសារទំនាក់ទំនងផ្ទៃក្នុងសហកាល របស់បក្សកុម្មុយនីស្តកម្ពុជា (២) សេចក្តីថ្លែងការណ៍ដែលចេញដោយ រដ្ឋាភិបាលវៀតណាម និង(៣) សេចក្តីរាយការណ៍ព័ត៌មានអន្តរជាតិ។ ឯកសារទាំង

---

[11] សំណើ, កថាខណ្ឌ ៧។

[12] សំណុំរឿង ០០៣ ឯកសារ D234.2, ឧសម្ព័ន្ធ ក, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ("ឧសម្ព័ន្ធរបស់សហព្រះរាជអាជ្ញាអន្តរជាតិ")។

[13] *ដូចជើងទំព័រខាងលើ.*, កថាខណ្ឌ ៨, ៣២។

អស់នេះពាក់ព័ន្ធជាមួយ បទចោទប្រកាន់នៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំង មាស មុត ព្រមទាំងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ កងទ័ពជើងទឹកកម្ពុជា នៅក្នុងដែនទឹក និងបណ្ដាកោះ ដែលអះអាងថាជាកម្មសិទ្ធិខ្លួន ដោយកម្ពុជាប្រជាធិបតេយ្យ រួមទាំងបទចោទប្រល័យពូជសាសន៍ ប្រឆាំង មាស មុត[14]។

២. <u>គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា (ឯកសារ ១៧ ដល់៤៣)</u>

11. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេត ដាក់ឯកសារចំនួន២៦ និងខ្សែវីដេអូមួយ ទៅក្នុងសំណុំរឿង០០៣ ដែលផ្ដល់នូវភស្តុតាងអំពីការបង្កើត ការវិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយទាំងបួន របស់បក្សកុម្មុយនីស្តកម្ពុជា[15]។

12. ឯកសារទាំងអស់នេះរួមមាន សេចក្ដីថ្លែងការណ៍ និងឯកសារបោះពុម្ពផ្សាយសហកាលរបស់បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងរបាយការណ៍វិភាគជាបន្តបន្ទាប់ និងកំណត់ត្រានៃសេចក្ដីថ្លែងការណ៍ ដែលធ្វើឡើងដោយ នួន ជា និងខៀវ សំផន ហើយដែលបង្ហាញពីលក្ខណៈព្រហ្មទណ្ឌដែលជាប់មកជាមួយ ក្នុងការអនុវត្តពិតប្រាកដ ឬដោយចេតនា នូវគោលនយោបាយទាំងនេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះសម្ភារៈទាំងនេះពាក់ព័ន្ធ ដល់ការបង្ហាញអំពីអត្ថិភាព វិសាលភាព និងគោលបំណងនានានៃ ផែនការឧក្រិដ្ឋកម្មរួម និងពីចេតនាប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញជាក់លាក់របស់ មាស មុត និងសហចារីរបស់គាត់ផងដែរ[16]។

13. ទោះបីថាមានទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន យុវនារីបដិវត្តជាច្រើនច្បាប់ នៅក្នុងសំណុំរឿងរួចហើយក៏ដោយ តែសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា នៅពេលពិនិត្យមើលរួមគ្នា សម្ភារៈដែលបានស្នើសុំបន្ថែម អាចផ្ដល់នូវទិដ្ឋភាពច្បាស់លាស់ជាង អំពី

---

[14] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១០។

[15] *ដូចជើងទំព័រខាងលើ.*, កថាខណ្ឌ ៣, ១១ ដល់១២។ គោលនយោបាយដូចដែលបានលើកឡើង ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណើ ដែលសម្ភារៈទាំងអស់នេះមានភាពពាក់ព័ន្ធគឺ៖ (១) ការបង្កើតនិងប្រតិបត្តិ "សហករណ៍" និងការដ្ឋានធ្វើពលកម្មដោយបង្ខំ។ (២) "ការរៀនសូត្រ" "សមាសធាតុមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរ និងក្រៅជួរកងទ័ព។ (៣) ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ ជាពិសេសជនជាតិវៀតណាម និងជនជាតិថៃ (ទាំងពិតប្រាកដ ឬតាមការគិត) រួមទាំងកងទ័ព និងអតីតកងទ័ព ជនស៊ីវិល និងជនបរទេស ដែលធ្វើដំណើរនៅក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យ។ (៤) ការរៀបការដោយបង្ខំទៅលើជនស៊ីវិល និងសមាជិកកងទ័ពបដិវត្តកម្ពុជា។

[16] សំណើ, កថាខណ្ឌ ១១ ដល់១៣។

គោលនយោបាយទាំងបួន ព្រមទាំងចំណុចលម្អិតពិសេសរបស់គោលនយោបាយ ដែលមិនអាចរកបាននៅទីកន្លែងផ្សេង[17]។

៣. ការទំនាក់ទំនង (ឯកសារ ៤៤ ដល់៥៧)

14. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេតដាក់ ឯកសារចំនួន១៤ ទាក់ទងនឹងការទំនាក់ទំនងផ្ទៃក្នុង របស់បក្សកុម្មុយនីស្តកម្ពុជា ចូលទៅក្នុងសំណុំរឿង ០០៣។ ឯកសារទាំងនោះភាគច្រើនជា របាយការណ៍និងទូរលេខ ដែលបានបញ្ជូនរវាងកងពលធំ និងអគ្គសេនាធិការ ហើយបានបង្ហាញអំពីរចនាសម្ព័ន្ធនៃការរាយការណ៍ នៅក្នុងកងទ័ពបដិវត្តកម្ពុជា និងការផ្សព្វផ្សាយនៅក្នុងកងទ័ពបដិវត្តកម្ពុជា នូវគោលនយោបាយដែលបានអនុម័ត។ ទូរលេខ និងរបាយការណ៍ដែលពាក់ព័ន្ធនឹងកងពលធំ របស់កងទ័ពបដិវត្តកម្ពុជាក្រៅពីឯកសារដែលលពាក់ព័ន្ធផ្ទាល់ទោនឹងសំណុំរឿង០០៣ គឺនៅតែមានភាពពាក់ព័ន្ធខ្លាំងក្នុងការកំណត់អំពីគំរូនៃទម្រង់ និងសារធាតុនៃការទំនាក់ទំនងរបស់ បក្សកុម្មុយនីស្តកម្ពុជាដែលមានភាពស្រដៀងគ្នាជាមួយ ការទំនាក់ទំនងជាមួយ មាស មុត[18]។

15. បន្ថែមលើនេះឯកសារទាំងអស់នេះ បង្ហាញពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងវៀតណាមជាមួយកម្ពុជាប្រជាធិបតេយ្យ ចំណែកឯកសារ៥៧ទៀត ផ្តល់ជាពិសេសនូវទិដ្ឋភាពច្បាស់លាស់ អំពីរចនាសម្ព័ន្ធសិទ្ធិអំណាច បុគ្គលិក និងការទំនាក់ទំនង ដែលដូច្នេះហើយបាននូវមូលដ្ឋាន នៃការយល់ដឹងអំពីរចនាសម្ព័ន្ធឋានានុក្រម ដែលពាក់ព័ន្ធមាស មុត និងកងពលធំ១៦៤[19]។

៤. មន្ទីរស-២១ (ឯកសារ ៥៨ ដល់៦២)

16. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេត ដាក់ចូលទៅក្នុងសំណុំរឿង ០០៣ នូវឯកសារចំនួនប្រាំ ដែលទាក់ទងផ្ទាល់ជាមួយមន្ទីរសន្តិសុខស-២១ ដោយលើកឡើងថា ឯកសារទាំងអស់នេះផ្តល់នូវភស្តុតាងផ្ទាល់ អំពីការបោសសម្អាតកម្មាភិបាលនៅក្នុងកងពលធំ១៦៤ ការសួរចម្លើយអ្នកទោសមន្ទីរស-២១ និងការដឹងឮ ព្រមទាំងការពាក់ព័ន្ធ របស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅទីនោះ[20]។

---

[17] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៤។

[18] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៥។

[19] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៧ ដល់១៨។

[20] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៩។

៥. ផែនទី (ឯកសារ ៦៣ ដល់៦៧)

17. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេត ដាក់ចូលទៅក្នុងសំណុំរឿង ០០៣ នូវឯកសារចំនួនប្រាំ ដែល ដើម្បីជួយដល់ការបង្ហាញ និងយល់ដឹងអំពីទីតាំងឧក្រិដ្ឋកម្មនានា អំពីលក្ខណៈរីករាលដាល និងជាប្រព័ន្ធ អំពីភាពជិតស្និទ្ធរបស់ មាស មុត និងអ្នកនៅក្រោមបង្គាប់របស់គាត់ ទៅនឹងឧក្រិដ្ឋកម្មទាំងនោះ និងអំពីព្រំប្រទល់នៃឃុំ ស្រុក តំបន់ និងភូមិភាគដែលពាក់ព័ន្ធ[21]។

៦. <u>ប្រតិចារឹកនៃសំណុំរឿង ០០២/០២ និងសម្ភារៈពាក់ព័ន្ធ (ឯកសារ ៦៨ ដល់១០៩)</u>

18. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេតដាក់ ឯកសារចំនួន៤១ ដែលរួមមានប្រតិចារឹកសំណុំរឿង ០០២/០២ កំណត់ហេតុស្តាប់ចម្លើយសាក្សី កំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពាក្យបណ្តឹងចំនួនមួយ និងសៀវភៅមួយក្បាល ចូលទៅក្នុងសំណុំរឿង ០០៣។ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងដោយទូលាយថា ប្រតិចារឹកមានផ្ទុកនូវភស្តុតាងរបស់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់ភាគច្រើនមានកំណត់ហេតុស្តាប់ចម្លើយ ឬភស្តុតាងដទៃទៀតនៅក្នុងសំណុំរឿង ០០៣ រួចទៅហើយ ហើយសក្ខីកម្មរបស់ពួកគាត់ នឹងបន្ថែមទៅលើភស្តុតាងទាំងនោះ ឬអនុញ្ញាតឲ្យយល់ដឹងកាន់តែប្រសើរ អំពីភស្តុតាងដែលមាននៅក្នុងសំណុំរឿង។ សម្ភារៈដែលពាក់ព័ន្ធជាមួយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបែបនេះ ក៏នឹងត្រូវបានបញ្ចូលផងដែរទៅក្នុងសំណើនេះ ប្រសិនបើមានភាពពាក់ព័ន្ធ[22]។

៧. <u>ឯកសារនានាជាមូលដ្ឋាននៃបញ្ជីមន្ទីរស-២១ របស់ ក.ស.ច.ស (ឯកសារ១១០ ដល់៨៥៦)</u>

19. នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ បន្ទាប់ពីបានពិនិត្យទៅលើឯកសារសហកាល របស់មន្ទីរស-២១ រួចមក ក.ស.ច.ស បានបង្កើតបញ្ជីមន្ទីរស-២១ របស់ក.ស.ច.ស ដែលបង្ហាញថា មនុស្សចំនួន១៥ ១០១ នាក់ ត្រូវបានកត់ត្រាជាអ្នកទោសមន្ទីរស-២១ ផ្អែកលើឯកសារសហកាលរបស់មន្ទីរស-២១ ដែលនៅសល់[23]។

[21] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២០។

[22] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២១, ២៤។

[23] សំណុំរឿង ០០៣ ឯកសារ D114/230.1.1, បញ្ជីមន្ទីរស-២១ របស់ក.ស.ច.ស, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦។

20. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឱ្យសហចៅក្រមស៊ើបអង្កេតដាក់ ឯកសារសហកាលចំនួន៧៥៦ ចូលទៅក្នុងសំណុំរឿង ០០៣ ដែលនឹងអនុញ្ញាតឱ្យភាគីនានា អាចធ្វើការវិភាគបានត្រឹមត្រូវ ទៅលើខ្លឹមសារនិងភាពត្រឹមត្រូវ នៃបញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស ដើម្បីផ្ទៀងផ្ទាត់ជាមួយអត្តិភាពរបស់បុគ្គលនីមួយៗ នៅមន្ទីរស-២១ ព្រមទាំងប្រភពដើម និងតួនាទីរបស់ពួកគេ។ ឯកសារដែលបានស្នើឡើង ឆ្លើយតបទៅនឹងឯកសារសហកាលរបស់មន្ទីរស-២១ ដែលជាមូលដ្ឋាននៃ បញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស ដូចមាននៅក្នុងឯកសារ D114/230.1.2 ដែលមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយ[24]។

**ខ. ចម្លើយតប**

21. មេធាវីការពារក្តីបានលើកជាទូទៅថា សំណើគួរត្រូវបានច្រានចោលដោយសារតែ (១) សំណើនេះមិនបានដាក់ទាន់ពេលវេលា ព្រោះសហព្រះរាជអាជ្ញាអន្តរជាតិ មានលទ្ធភាពពិនិត្យមើលសំណុំរឿង តាំងពីសំណុំរឿងបានចាប់ផ្តើមម្ល៉េះ។ សហព្រះរាជអាជ្ញាអន្តរជាតិទទួលបាន ឬមានលទ្ធភាពចូលពិនិត្យ សម្ភារៈដែលបានស្នើសុំភាគច្រើន ក្នុងរយៈពេលរាប់ខែ ឬរាប់ឆ្នាំ ហើយគាត់បានទទួលការជូនដំណឹង នៅពេលដែលសម្ភារៈនៅក្នុងសំណុំរឿង ០០២ ឬនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង[25] (២) សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានពន្យល់ថា ហេតុអ្វីបានជាមានភាពយឺតយ៉ាវបែបនេះ[26] (៣) បណ្តាលឱ្យមានការពន្យាពេលដោយមិនសមស្រប នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបែបនេះ ដោយសារតែកិច្ចស៊ើបអង្កេត នឹងតម្រូវឱ្យបើកចំហ ដើម្បីអនុញ្ញាតឱ្យមេធាវីការពារក្តី មានពេលវេលាក្នុងការត្រួតពិនិត្យមើលសម្ភារៈ ដែលតាមការប៉ាន់ប្រមាណត្រូវការយ៉ាងហោចណាស់រយៈពេលបួនខែ ហើយនិងដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ បន្តបន្ទាប់ទៀត[27] (៤) ការបន្ថែមសម្ភារៈដែលបានស្នើសុំ នឹងបណ្តាលឱ្យសំណុំរឿងមានឯកសារជាន់គ្នាច្រើន ដោយសារតែសម្ភារៈដែលបានស្នើសុំ មួយចំនួនស្ថិតក្នុងសំណុំ

[24] សំណើ, កថាខណ្ឌ ២៦, ២៨។

[25] ចម្លើយតប, កថាខណ្ឌ ៩, ១៨ ដល់២៥។

[26] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១០។

[27] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១១ ដល់១៣។

រឿងរួចហើយ ឬហាក់ដូចជាមាននៅក្នុងសំណុំរឿងរួចហើយ[28] និង (៥) សម្ភារៈមួយចំនួនដែលបានស្នើសុំ ហាក់ដូចជាជាន់គ្នា ឬជាឯកសារជាន់គ្នា[29]។

22. មេធាវីការពារក្តីមិនជំទាស់ ចំពោះការបញ្ចូលប្រតិចារឹក និងសម្ភារៈពាក់ព័ន្ធរបស់សាក្សីដែលបានផ្តល់ភស្តុតាងរួចហើយ នៅក្នុងសំណុំរឿង០០៣ ទៅក្នុងសំណុំរឿង ដោយសារការនេះនឹងអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត និងភាគីអាចធ្វើការវាយតម្លៃបានល្អជាងមុន ទៅលើភស្តុតាងរបស់សាក្សីទាំងនោះ។ មេធាវីការពារក្តីជំទាស់ចំពោះ ប្រតិចារឹកសំណុំរឿង០០២/០២ដែលនៅសល់ និងសម្ភារៈពាក់ព័ន្ធដទៃទៀត ដែលមិនត្រូវដាក់បញ្ចូលដោយសារតែ សម្ភារៈទាំងនោះមានតម្លៃភស្តុតាងទាប និងដោយសារតែពេលវេលា នៃការដាក់សំណើ[30]។

23. មេធាវីការពារក្តីជំទាស់ចំពោះឯកសារ ដែលទាក់ទងនឹងបញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឡើយ ដោយសារតែអាចចូលពិនិត្យមើលឯកសារទាំងនោះ នៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ដូច្នេះមិនចាំបាច់ដែលត្រូវបញ្ចូល ទៅក្នុងសំណុំរឿង សម្រាប់គោលបំណងដែល សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ គឺវិភាគបញ្ជីមន្ទីរស-២១របស់ ក.ស.ច.ស ដើម្បីបញ្ជាក់អំពីអត្តភាព ប្រភពដើម និងតួនាទីរបស់បុគ្គលនីមួយៗ នៅមន្ទីរស-២១[31]។

24. ប្រសិនបើសំណើត្រូវបានអនុញ្ញាតទាំងស្រុង ឬដោយផ្នែកនោះ មេធាវីការពារក្តីស្នើសុំថា កិច្ចស៊ើបអង្កេតនៅបន្តបើក ក្នុងរយៈពេលសមស្របមួយ ដើម្បីឲ្យអាចធ្វើការត្រួតពិនិត្យទៅលើឯកសារដែលបានស្នើសុំ ("សំណើរបស់មេធាវីការពារក្តី")។

## III. **ការពិភាក្សា**

### ក. បទដ្ឋានសម្រាប់ការវាយតម្លៃ លើសំណើសុំបំពេញកិច្ចស៊ើបសួរ

25. អង្គបុរេជំនុំជម្រះបានបញ្ជាក់នាពេលកន្លងមកថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ “*ត្រូវបំពេញលក្ខខណ្ឌត្រួតគ្នាចំនួនពីរ [...] ពោលគឺសំណើសុំត្រូវតែ (១) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើដោយមានការបញ្ជាក់ឲ្យបានច្បាស់លាស់ ("*

[28] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ១៤ ដល់១៦, ២១។

[29] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ១៨ ដល់១៩។

[30] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ២៤។

[31] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ២៥។

*លក្ខខណ្ឌនៃភាពច្បាស់លាស់") និង (២) បង្ហាញឲ្យបានពិស្តារ អំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរ ដែលបានស្នើសុំ [...] មានការ "ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត" ជាបឋម ("លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម")*[32] ។

26. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឲ្យភាគីដែលស្នើសុំ "ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឲ្យបានច្បាស់ដល់ សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការស៊ើបសួរ"[33]។ ជាលទ្ធផលមិនមានការតម្រូវឲ្យខ្ញុំ ត្រូវអនុញ្ញាតតាមសំណើទូទៅ ឬសំណើបែបស្មាននោះឡើយ ប៉ុន្តែភាគីដែលស្នើសុំចាំបាច់ត្រូវចង្អុលបង្ហាញឲ្យបានច្បាស់លាស់ អំពីវត្តមានរបស់ភស្តុតាង ដែលខ្លួនចង់ស្វែងរក[34]។ ឧទាហរណ៍អង្គបុរេជំនុំជម្រះបានសម្រេចថា សំណើដែលមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីចំនួនឯកសារដែលចង់ស្វែងរក ឬអំពីទីតាំងច្បាស់លាស់ ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនេះ[35]។

27. លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម មានលក្ខខណ្ឌរងចំនួនពីរ។ ទីមួយសំណើសុំចាំបាច់ត្រូវតែ "មានការពាក់ព័ន្ធជាមួយនឹងវិសាលភាព នៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿង

---

[32] សំណុំរឿង ០០២ ឯកសារ D365/2/17, សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮ របស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ("សាលដីកាស្តីពីការពិចារណាឡើងវិញ"), កថាខណ្ឌ ៤៧។ *សូមមើលផងដែរ*, សំណុំរឿង ០០៤/២ ឯកសារ D320/1/1/4, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើសំណើលើកទី១២របស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧, កថាខណ្ឌ ១៣។

[33] សាលដីកាស្តីពីការពិចារណាឡើងវិញ, កថាខណ្ឌ ៤៨។

[34] *ដូចជើងទំព័រខាងលើ.*, កថាខណ្ឌ ៤៨, ៧៣។ សំណុំរឿង ០០២ ឯកសារ D100/9/2, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេត ទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ ៣១។ សំណុំរឿង ០០២ ឯកសារ D164/4/13, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចសុំស្វែងរក ភស្តុតាងដោះបន្ទុកនៅក្នុង ឃ្លាំងផ្ទុកឯកសាររួម, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ ៣៨ ដល់៣៩។ សំណុំរឿង ០០២ ឯកសារ D273/3/5, សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើលើកទី១៨របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០, កថាខណ្ឌ ១៩ ដល់២០, ២៦, ២៩។

[35] សាលដីកាស្តីពីការពិចារណាឡើងវិញ, កថាខណ្ឌ ៤៨។

ឲ្យស៊ើបសួរបន្ថែម"[36]។ ទីពីរសំណើសុំ "ត្រូវតែរៀបរាប់លម្អិតអំពីមូលហេតុអ្វី បានជាព័ត៌មានដែលបានស្នើសុំ នឹងនាំឲ្យរកឃើញនូវការពិត"[37]។ ការនេះតម្រូវឲ្យភាគីស្នើសុំកំណត់ពីចំណងទាក់ទងជាបឋម រវាងព័ត៌មានដែលបានស្វែងរក តាមរយៈកិច្ចដែលបានស្នើសុំ និងបញ្ហាដែលស្ថិតនៅក្នុង វិសាលភាពនៃកិច្ចស៊ើបសួរ[38]។ ក្នុងករណីដែលសំណើពាក់ព័ន្ធ ភស្តុតាងដោះបន្ទុក ភាគីស្នើសុំចាំបាច់ត្រូវតែបង្ហាញ នូវមូលហេតុជាបឋមដែលថា កិច្ចស៊ើបសួរអាចនាំឲ្យទទួលបាន នូវភស្តុតាងដោះបន្ទុក[39]។

**ខ. ការវិភាគទៅលើសំណើសុំ**

28. ខ្ញុំជឿជាក់ថាសំណើសុំ បានបំពេញនូវលក្ខខណ្ឌនៃភាពច្បាស់លាស់។ ឧបសម្ព័ន្ធរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ បានកំណត់និងបានរៀបរាប់យ៉ាងជាក់លាក់ អំពីឯកសារនីមួយៗ ដែលបានស្នើសុំដាក់ចូលទៅក្នុងសំណុំរឿង។ ខ្ញុំបានវិភាគថាតើសំណើសុំ បានបំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋមដែរឬយ៉ាងណា ទាក់ទងទៅនឹងឯកសារនីមួយៗ ដូចរៀបរាប់នៅផ្នែកខាងក្រោម។

១. <u>ជម្លោះប្រដាប់អាវុធអន្តរជាតិ (ឯកសារ១ ដល់១៦)</u>

29. ខ្ញុំជឿជាក់ថាឯកសារ១ ដល់៩ និងឯកសារ១១ ដល់១៦ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម ដោយសារតែឯកសារទាំងអស់នេះ មានភាពពាក់ព័ន្ធផ្នែកបរិបទ ជាមួយអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

30. ចំពោះឯកសារ១០ ដែលរួមមានសុន្ទរកថារបស់ ខៀវ សំផន នៅក្នុងឱកាសខួបលើកទីបី ថ្ងៃរំដោះទីក្រុងភ្នំពេញនោះ គឺមាននៅក្នុងសំណុំរឿង ០០៣ រួចទៅហើយ ដោយមានលេខឯកសារ D69.1.21។ ហេតុដូច្នេះសំណើនេះទៅជាអាសារឥតការ សម្រាប់ឯកសារ១០។

២. <u>គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា (ឯកសារ ១៧ ដល់៤៣)</u>

---

[36] សាលដីកាស្ដីពីការពិចារណាឡើងវិញ, កថាខណ្ឌ ៤៩។

[37] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៥០។

[38] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៥០ ដល់៥១។

[39] សំណុំរឿង ០០២ ឯកសារ D353/2/3, សាលដីកាលើបណ្ដឹងឧទ្ធរណ៍ របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេច លើសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយមេធាវីការពារក្ដី អៀង ធីរិទ្ធ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០, កថាខណ្ឌ ៤៧។

31. ខ្ញុំជឿជាក់ថាឯកសារ១៧ ដល់២២ និងឯកសារ២៤ ដល់៤៣ មានភាពពាក់ព័ន្ធផ្នែកបរិបទ ជាមួយបញ្ហា នៃគោលនយោបាយ និងការអនុវត្តគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា។

32. ប៉ុន្តែឯកសារ២៣ ជាសម្រង់ចេញពីឯកសារវែង ដែលមាននៅក្នុងសំណុំរឿង០០៣ រួចទៅហើយ ដោយមានលេខឯកសារ D1.3.22.1។ ហេតុដូច្នេះមិនចាំបាច់ត្រូវដាក់ឯកសារ២៣ ទៅក្នុងសំណុំរឿងនោះឡើយ។ ហេតុដូច្នេះសំណើនេះទៅជាអាសារឥតការ សម្រាប់ឯកសារ២៣។

៣. <u>ការទំនាក់ទំនង (ឯកសារ ៤៤ ដល់៥៧)</u>

33. ប្រហែលគ្នានេះខ្ញុំជឿជាក់ថាឯកសារ៤៤ ដល់៥៣ និងឯកសារ៥៧ មានភាពពាក់ព័ន្ធផ្នែកបរិបទ ជាមួយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួន ព្រមទាំងពាក់ព័ន្ធជាមួយរចនាសម្ព័ន្ធនៃការរាយការណ៍ និងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជានិងវៀតណាម។

34. ឯកសារ ៥៤ ដល់៥៦ បានមកពីក្រុមប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាមេរិក នៅក្នុងខែឧសភា ឆ្នាំ ១៩៧៥ ហើយមានជាប់ពាក់ព័ន្ធជាមួយ ការវាយប្រយុទ្ធគ្នារវាងវៀតណាម និងកម្ពុជានៅតាមបណ្តាកោះនានា ចន្លោះពីខែមេសា ដល់ខែឧសភា ឆ្នាំ១៩៧៥ និងឧប្បត្តិហេតុ Mayaguez។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ឯកសារទាំងអស់នេះមានភាពពាក់ព័ន្ធ ដោយសារតែឯកសារទាំងនេះបង្ហាញពីអត្ថិភាព នៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងស្ថានភាពនៅលើបណ្តាកោះ ដែលរដ្ឋទាំងពីរអះអាងពីអធិបតេយ្យភាព នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ និងបង្ហាញពីការស្លាប់របស់អ្នកទោស ដែលបានឃុំខ្លួននៅលើកោះឯនាយសមុទ្រ និងនៅមន្ទីរសន្តិសុខវត្តឥន្ទញាណ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងពលធំ ១៦៤[40]។

35. ចំណែកឯកសារ៥៤ បានពិភាក្សាពាក់ព័ន្ធតែនឹងជម្រើសនានា ដែលរដ្ឋាភិបាលអាមេរិកអាចជ្រើសរើស ដើម្បីរំដោះយកកប៉ាល់ Mayaguez និងជនស៊ីវិលនៅលើកប៉ាល់នោះ ដែលត្រូវបានចាប់យកទៅកោះតាំង។ ឯកសារ ៥៥ មានកំណត់ហេតុកិច្ចប្រជុំតែមួយ ដូចគ្នានឹងឯកសារ ៥៤ ដែរ ហើយឯកសារ៥៦ ពិភាក្សាសំខាន់តែទៅលើ ការកំណត់ពេលវេលានិងកម្លាំងរបស់កងអន្តរាគមន៍អាមេរិក។ មានការពិភាក្សាតិចតួច ឬសឹងមិនមានតែម្តង ដែលបានផ្តោត

[40] សំណើ, កថាខណ្ឌ ១៧។

ទៅលើជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ឬអំពីរចនាសម្ព័ន្ធនយោបាយ ឬរចនាសម្ព័ន្ធបញ្ជាការរបស់ កម្ពុជាប្រជាធិបតេយ្យ។ ដោយហេតុណោះហើយខ្ញុំសម្រេចថាឯកសារ៥៤ ឯកសារ៥៥ និងឯកសារ៥៦ មិនបានបំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋមឡើយ ដូច្នេះត្រូវបដិសេធចំពោះសំណើសុំដាក់ឯកសារនេះ ចូលទៅក្នុងសំណុំរឿង។

៤. <u>មន្ទីរស-២១ (ឯកសារ៥៨ ដល់៦២)</u>

36. ខ្ញុំជឿជាក់ថាឯកសារ៥៨ ឯកសារ៦១ និងឯកសារ៦២ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម ដោយសារតែឯកសារទាំងនេះ មានសម្ភារៈដែលផ្ទុយគ្នាយ៉ាងសំខាន់ អំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងតំបន់គ្រប់គ្រង ព្រមទាំងរចនាសម្ព័ន្ធអំណាចរបស់កំពង់សោម។

37. ឯកសារ៥៩ និងឯកសារ៦០ ពាក់ព័ន្ធទៅនឹងចម្លើយសារភាពនៅមន្ទីរស-២១។ ដូចដែលខ្ញុំបានបញ្ជាក់កន្លងមក ក.ស.ច.ស នឹងមិនដាក់ចម្លើយសារភាពនៅមន្ទីរស-២១ទាំងស្រុងចូលទៅក្នុងសំណុំរឿងឡើយ គឺក.ស.ច.ស នឹងដាក់ត្រឹមតែផ្នែកខ្លះនៃចម្លើយសារភាព ដែលមានចំណារពាក់ព័ន្ធប៉ុណ្ណោះ[41]។ ការអនុវត្តបែបនេះគឺស្របតាម មតិរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ចម្លើយសារភាពដែលទទួលបានតាមរយៈ ការបង្ខំផ្លូវកាយឬផ្លូវចិត្តត្រូវបានហាមឃាត់មិនឲ្យប្រើធ្វើជាភស្តុតាងឡើយ[42] ព្រោះចម្លើយសារភាព ឬព័ត៌មានដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម "មិនអាចជឿជាក់បានផ្ទៃក្នុង" ព្រោះជនរងគ្រោះដោយការធ្វើទារុណកម្ម នឹងប្រហែលជានិយាយអ្វី ដើម្បីគ្រាន់តែបញ្ចប់ទារុណកម្មប៉ុណ្ណោះ[43]។

38. ឯកសារ៥៩គឺជាឯកសារបកប្រែ ចំណារនិងផ្នែកដែលគូសបង្ហាញដោយ ចំណារនៃចម្លើយសារភាពនៅមន្ទីរស-២១ប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថាឯកសារនេះបំពេញបានតាម លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម ដោយសារតែឯកសារនេះមានភស្តុតាង ទាក់ទងនឹងការគ្រប់គ្រង

[41] សំណុំរឿង ០០៣ ឯកសារ D223, ដីកាសម្រេចរួមលើសំណើសុំ បំពេញកិច្ចស៊ើបសួរលើកទីមួយ លើកទីពីរ និងលើកទីបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៦, កថាខណ្ឌ ៤៣។

[42] សំណុំរឿង ០០២ ឯកសារ F26/12, សេចក្តីសម្រេចលើសេចក្តីជំទាស់ ទៅនឹងបញ្ជីឯកសារ សំអាងហេតុពេញលេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥, កថាខណ្ឌ ៣១។

[43] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៤២។

របស់ មាស មុត ទៅលើកងពលធំ១៦៤ និងគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជាចំពោះជនក្បត់។ ហេតុដូច្នេះខ្ញុំអនុញ្ញាតតាមសំណើ សុំដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង។

39. ឯកសារ៦០យោងទៅរកឯកសារជាច្រើន ដែលមានលេខឯកសារ E3/150 ដែលឯកសារទាំងអស់នេះត្រូវបានបញ្ចូលទៅក្នុងសំណើសុំ ដោយការយោងនៅក្នុងឧបសម្ព័ន្ធរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សំដៅទៅរកលេខ ERN ទាំងអស់។ ឯកសារដែលមានលេខ E3/150 និងមានលេខ ERN ពី 00224085-00224086 (EN) គឺជាឯកសារបកប្រែនៃចំណារ របស់ចម្លើយសារភាពនៅមន្ទីរស-២១។ ខ្ញុំជឿជាក់ថាឯកសារនេះ បំពេញបានតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម ដោយសារតែឯកសារនេះមានភស្តុតាង ទាក់ទងនឹងការគ្រប់គ្រងរបស់ មាស មុត ទៅលើកងពលធំ១៦៤ និងគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជាចំពោះជនក្បត់។ ហេតុដូច្នេះខ្ញុំអនុញ្ញាតតាមសំណើ សុំដាក់ឯកសារនេះ និងឯកសារបកប្រែជាភាសាបារាំង[44] ចូលទៅក្នុងសំណុំរឿង។

40. ទោះជាយ៉ាងនេះក្តីឯកសារ៦០ មាននូវចម្លើយសារភាពច្បាប់ដើម[45] និងឯកសារបកប្រែសម្រង់ដែលបានជ្រើសរើសខ្លះៗ ពីចម្លើយសារភាព[46] ដែលហេតុនេះហើយទើបខ្ញុំសម្រេចបដិសេធសំណើសុំដាក់ផ្នែកទាំងអស់នេះនៃឯកសារ៦០ ចូលទៅក្នុងសំណុំរឿង។

<u>៥. ផែនទី (ឯកសារ ៦៣ ដល់៦៧)</u>

41. បន្ទាប់ពីបានពិនិត្យមើលរួចហើយ ខ្ញុំជឿជាក់ថាឯកសារ៦៣ ដល់ឯកសារ៦៧ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម ដោយសារតែផែនទីនីមួយៗ បានផ្តល់នូវព័ត៌មានលម្អិតបន្ថែម ទាក់ទងព័ត៌មានភូមិសាស្ត្រគន្លឹះ នៃការចោទប្រកាន់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម

៦. <u>ប្រតិចារឹកនៃសំណុំរឿង ០០២/០២ និងសម្ភារៈពាក់ព័ន្ធ (ឯកសារ ៦៨ ដល់១០៩)</u>

42. ខ្ញុំជឿជាក់ផងដែរថាឯកសារ៦៨ ដល់៨០ និងឯកសារ៨២ ដល់១០៩ បានផ្តល់នូវព័ត៌មានបន្ថែម ចំពោះភស្តុតាងដែលមានរួចហើយនៅក្នុងសំណុំរឿង។

---

[44] សំណុំរឿង ០០២ ឯកសារ E3/150 ដោយមានលំដាប់លេខ ERN 00235668-00235568 (ភាសាបារាំង)។

[45] សំណុំរឿង ០០២ ឯកសារ E3/150 ដោយមានលំដាប់លេខ ERN 00174375-00174391។

[46] សំណុំរឿង ០០២ ឯកសារ E3/150 ដោយមានលំដាប់លេខ ERNs 00823631-00823643 (ភាសាអង់គ្លេស), 00773063-00773076 (ភាសាបារាំង)។

43. ទោះជាយ៉ាងនេះក្តីឯកសារ៨១ ដែលជាប្រតិចារឹករបស់ អ៊ី វ៉ុន នៅក្នុងសវនាការសំណុំរឿង ០០២/០២ មិនបានផ្តល់ភស្តុតាងសម្ភារៈណាមួយឡើយ ទាក់ទងការសម្លាប់ "ខ្មាំង" ឬការកំណត់គោលដៅទៅលើក្រុមជាក់លាក់ណាមួយ ហើយក៏មិនបានផ្តល់ភស្តុតាងថា ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជា "ខ្មាំង" ឬត្រូវបានកំណត់គោលដៅជាក់លាក់ឡើយ។ ហេតុដូច្នេះខ្ញុំមិនជឿថាឯកសារ៨១ បំពេញតាមលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋមឡើយ ដូច្នេះខ្ញុំបដិសេធទៅលើសំណើសុំដាក់ឯកសារនេះ ចូលទៅក្នុងសំណុំរឿង។

៧. <u>ឯកសារនានាជាមូលដ្ឋាននៃបញ្ជីមន្ទីរស-២១ របស់ ក.ស.ច.ស (ឯកសារ១១០ ដល់៨៥៦)</u>

44. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំ ឲ្យសហចៅក្រមស៊ើបអង្កេតដាក់ចូលទៅក្នុងសំណុំរឿង នូវឯកសារសហកាលរបស់មន្ទីរស-២១ ចំនួន៧៥៦ ដែលឆ្លើយតបចំពោះឯកសារនានា ជាមូលដ្ឋាននៃបញ្ជីមន្ទីរស-២១ របស់ក.ស.ច.ស ដូចមានរៀបរាប់លម្អិតនៅក្នុងឯកសារ D114/230.1.2 ហើយដែលមិនទាន់មាននៅឡើយនៅក្នុងសំណុំរឿង ០០៣[47]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ឯកសារទាំងអស់នេះគួរត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ដើម្បីអាចឲ្យធ្វើការវាយតម្លៃ សម្រាប់ភាពត្រឹមត្រូវនៃបញ្ជីមន្ទីរស-២១ របស់ ក.ស.ច.ស[48]។

45. ខ្ញុំមិនជឿជាក់ទៅលើភាពចាំបាច់ សម្រាប់កិច្ចស៊ើបអង្កេតបែបនេះឡើយ។ បញ្ជីមន្ទីរស-២១ របស់ក.ស.ច.ស មានឈ្មោះមនុស្សចំនួន១៥ ១០១ នាក់ ហើយត្រូវបានចងក្រងឡើងដោយអ្នកវិភាគ របស់ ក.ស.ច.ស បន្ទាប់ពីបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ អស់រយៈពេលជាង២៤ ខែ ទៅលើបណ្តាឯកសារសហកាល ដែលប្រមូលបានមកពី សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា[49]។ ផ្អែកទៅលើវិធីសាស្ត្រម៉ត់ចត់ និងរឹងមាំ ដែលអ្នកវិភាគរបស់ក.ស.ច.ស បានអនុវត្ត ក្នុងការចងក្រងបញ្ជីនេះ ខ្ញុំជឿជាក់ថា បញ្ជីមន្ទីរស-២១ របស់ក.ស.ច.ស បានផ្តល់នូវបញ្ជីដែលអាចជឿជាក់បានគ្រប់គ្រាន់ សម្រាប់គោលបំណងនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣។ ហេតុដូច្នេះមិនចាំបាច់ដែល

---

[47] សំណើ, កថាខណ្ឌ ២៦, ២៨។

[48] សំណើ, កថាខណ្ឌ ២៧។

[49] សំណុំរឿង ០០៤ ឯកសារ D322/8, សេចក្តីសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សម្ភារៈរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅក្នុងសំណុំរឿង ០០៤, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦, កថាខណ្ឌ ៤៦ ដល់៤៧។

ត្រូវដាក់បន្ទុកបន្ថែម ទៅលើសំណុំរឿង នូវឯកសារបន្ថែមចំនួន៧៥៦ឯកសារ សម្រាប់គោលបំណងនៃការធ្វើឡើងវិញនូវការវាយតម្លៃ ដែលក.ស.ច.សបានអនុវត្តរួចហើយ។

46. ហេតុដូច្នេះខ្ញុំសូមបដិសេធសំណើទាក់ទង ឯកសារ១១០ ដល់៨៦៥។

**គ. ការជំទាស់របស់មេធាវីការពារក្តី**

47. ខ្ញុំយល់ស្របជាមួយមេធាវីការពារក្តីដែលថា សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើសុំឯកសារ ដែលមានចំនួនយ៉ាងច្រើន បន្ទាប់ពីបានបញ្ចប់កិច្ចស៊ើបអង្កេត ដែលការនេះធ្វើឲ្យសំណើមានលក្ខណៈយឺតយ៉ាវជាបឋម។ ទោះជាយ៉ាងនេះក្តី ដោយសារតែខ្ញុំសម្រេចថា មានតែមួយផ្នែកតូចប៉ុណ្ណោះនៃសំណើ ដែលមានភាពពាក់ព័ន្ធ ខ្ញុំមិនចាត់ទុកថា ការដាក់ឯកសារនេះនឹងបណ្តាលឲ្យ មានការពន្យាពេលដោយមិនសមហេតុផល ចំពោះកិច្ចដំណើរការនីតិវិធី ឬបានរំលោភបំពានទៅលើសិទ្ធិ ទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់លោក មាស មុត ឡើយ។

48. ប្រហែលគ្នានេះ ដោយសារតែខ្ញុំអនុញ្ញាតតែមួយផ្នែកតូចនៃសំណើ ខ្ញុំជឿជាក់ថា ឯកសារនេះនឹងមិនជាន់គ្នាច្រើនឡើយនៅក្នុងសំណុំរឿង ហើយឯកសារទាំងនេះក៏មិនបង្កើតឲ្យមានការជាន់គ្នា ឬដូចគ្នាដែលមិនចាំបាច់ សម្រាប់ភស្តុតាងឡើយ។

49. ចំពោះសំណើរបស់មេធាវីការពារក្តី ខ្ញុំកត់សម្គាល់ថា[50] ទោះបីជាវិធាន ៦៦(១) នៃវិធានផ្ទៃក្នុងតម្រូវថា បន្ទាប់ពីចេញសេចក្តីជូនដំណឹង អំពីការបិទកិច្ចស៊ើបសួរ ភាគីទាំងអស់មានរយៈពេល១៥ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែមក៏ដោយ តែវិធានផ្ទៃក្នុងមិនបានពិចារណាជាក់ច្បាស់ ថាតើរយៈពេលបន្ថែមសម្រាប់ សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ("រយៈពេលបន្ថែម") ចាំបាច់ត្រូវតែផ្តល់ជូនដែរឬយ៉ាងណា ដើម្បីសម្របសម្រួលសម្រាប់សម្ភារៈថ្មីដែលត្រូវដាក់ចូលទៅក្នុងសំណុំរឿង បន្ទាប់ពីមានសេចក្តីជូនដំណឹង អំពីការបិទកិច្ចស៊ើបសួរ។ សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងក្រោម ខ្ញុំជឿជាក់ថាវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង គ្រាន់តែតម្រូវឲ្យមានរយៈពេលមួយ សម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានសេចក្តីជូនដំណឹងដំបូង អំពីការបិទកិច្ចស៊ើបសួរប៉ុណ្ណោះ។

50. ច្បាប់ទូទៅរបស់កម្ពុជា ដែលខ្ញុំត្រូវពឹងផ្អែកលើ ក្នុងករណីដែលវិធានផ្ទៃក្នុង មិនមានចែងលម្អិតនោះ បានគាំទ្រដល់ការបកស្រាយដែលថា មិនតម្រូវឲ្យមានរយៈពេលបន្ថែមឡើយ។

---

[50] សូមមើល សំណុំរឿង ០០៤/២ ឯកសារ D334/2, [កោសលប់] សេចក្តីជូនដំណឹងលើកទីពី អំពីការបិទបញ្ចប់ការស៊ើបសួរប្រឆាំងអោ អាន, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧, កថាខណ្ឌ ១២, ១៤ ដល់១៥។

ខ្ញុំកត់សម្គាល់ថាមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងយ៉ាងច្បាស់អំពីសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលអាចស្នើឡើងដោយព្រះរាជអាជ្ញាតែប៉ុណ្ណោះ តាមមាត្រា ១៣២ ហើយមេធាវីការពារក្តីមិនអាចស្នើសុំបានឡើយ បើតាមមាត្រា១៣៣ នៅពេលដែលការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ត្រូវបានផ្ញើជូនភាគីទាំងអស់[51]។ ទោះបីថាអាចមានការជំទាស់ ចំពោះការបកស្រាយតាមពាក្យពេចន៍ថា ការស៊ើបអង្កេតត្រូវបានបិទបញ្ចប់ តែនៅពេលមានដីកាដំណោះស្រាយក៏ដោយ (មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា) ដែលដូច្នេះហើយធ្វើឲ្យពាក្យពេចន៍នៃមាត្រា ១៣៣ ហាក់ដូចជាអនុវត្តដោយផ្ទាល់ រហូតដល់ចំណុចនោះ នៅក្នុងកិច្ចដំណើការនីតិវិធី ហើយអាចអនុញ្ញាតឲ្យមេធាវីការពារក្តី ដាក់សំណើសុំរហូតដល់ត្រឹម ការចេញដីកាដំណោះស្រាយក៏ដោយ តែមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងដូចគ្នាអំពីព្រះរាជអាជ្ញា ហើយខ្ញុំពិចារណាថាមាត្រា ២៤៦ ជាវិធានមានលក្ខណៈពិសេស សម្រាប់ស្ថានភាពក្រោយសេចក្តីជូនដំណឹង អំពីការបិទកិច្ចស៊ើបសួរ ជាចំណុចដែលដកចេញនូវរាល់សំណើសុំ បំពេញកិច្ចស៊ើបសួរណាមួយ ដោយមេធាវីការពារក្តី តាមវិធានទូទៅនៃមាត្រា ១៣៣ បន្ទាប់ពីមានសេចក្តីជូនដំណឹង អំពីការបិទកិច្ចស៊ើបសួរ។ បើមិនដូច្នេះទេការយោងជាក់លាក់ ទៅលើសិទ្ធិរបស់ព្រះរាជអាជ្ញា នៅក្នុងមាត្រា ១៣២ ហើយដកចេញក្នុងពេលជាមួយគ្នា នូវការយោងដូចគ្នាទៅរកសិទ្ធិរបស់មេធាវីការពារក្តី នៅក្នុងមាត្រា ១៣៣នោះ នឹងមិនមានន័យអ្វីឡើយ។ ដោយសារតែការដកចេញនេះ មានផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតមាន សម្រាប់តួនាទីរបស់មេធាវីការពារក្តី វាហាក់ដូចជាមិនមែនជាកំហុសឆ្គងឡើយ សម្រាប់ការលប់ចោលចំណុចនេះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ក្នុងន័យនេះច្បាប់ដែលមានចែងក្នុងវិធានផ្ទៃក្នុង មានការកែសម្រួលឲ្យប្រសើររួចហើយ ទាក់ទងទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដោយវិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យមេធាវីការពារក្តី និងភាគីដទៃទៀត មានពេលវេលា១៥ថ្ងៃ ដើម្បីដាក់សំណើសុំ។

51. ខ្ញុំពិចារណាថាមិនចាំបាច់ ត្រូវផ្តល់ឱកាសបន្ថែមណាមួយឡើយ លុះត្រាតែសម្ភារៈដែលបានដាក់ចូលទៅក្នុងសំណុំរឿង មានចំនួនច្រើនហួសហេតុ ហើយតម្រូវឲ្យមានការប្រឹងប្រែងខ្លាំង ពីភាគីដែលប៉ះពាល់ ក្នុងការវិភាគសម្ភារៈទាំងនោះ ដែលអាចនាំទៅដល់ភាពលំបាកធ្ងន់ធ្ងរ ប្រសិនបើភាគីនេះមិនបានទទួលពេលវេលាបន្ថែម ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរថ្មីដែលកើតចេញពីការវិភាគរបស់ពួកគេ។

---

[51] *សូមមើលផងដែរ, ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមានចំណារ,* 2nd Ed., ឆ្នាំ ២០១៥, ទំព័រ ៩៨។

52. ខ្ញុំជឿជាក់ថាឯកសារដែលបានដាក់ចូលទៅក្នុងសំណុំរឿង យោងតាមសេចក្តីសម្រេចនេះ មិនមានចំនួនច្រើនហួសហេតុ ហើយក៏មិនតម្រូវឱ្យមានការប្រឹងប្រែងខ្លាំងក្លា ដោយមេធាវីការពារក្តីឡើយ ក្នុងការវិភាគទៅលើសម្ភារៈទាំងនោះ។ ហេតុដូច្នេះខ្ញុំមិនផ្តល់ដល់មេធាវីការពារក្តី នូវការពន្យាពេលបន្ថែម ដើម្បីពិនិត្យមើលលើសម្ភារៈ និងធ្វើការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមណាមួយឡើយ។

**សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ÷ ខ្ញុំ**

53. **ប្រកាសថា** សំណើសុំទៅជាអាសារឥតការ ចំពោះឯកសារ ១០ និង២៣

54. **បដិសេធ** សំណើទាក់ទងឯកសារ ៥៤ ដល់៥៦, ឯកសារ៦០ (ត្រឹមកម្រិតដែលមានចែងក្នុងសេចក្តីសម្រេចនេះ) ឯកសារ ៨១ និងឯកសារ ១១០ ដល់៨៦៥

55. **អនុញ្ញាត** តាមសំណើចំពោះឯកសារ ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ នៃសេចក្តីសម្រេចនេះ

56. **បដិសេធ** សំណើរបស់មេធាវីការពារក្តី

57. **បង្គាប់ដល់** ក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យដាក់ចូលទៅក្នុងសំណុំរឿង ០០៣ នូវឯកសារដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ នៃសចក្តីសម្រេចនេះ។

សេចក្តីសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ចំណែកឯកសារបកប្រែជាភាសាខ្មែរនឹងដាក់ជូននៅពេលក្រោយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

ចៅក្រម Michael Bohlander

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**Internationa Reserve Co-Investigating Judges**

**Co-juges d’instruction international reséive**